វិទ្យាល័យ CAMBERWELL (ឃែមបើវែល)

កម្មវិធីសម្រាប់សិស្សអន្តរជាតិ

រដ្ឋវិចតូរៀ ប្រទេសអូស្ត្រាលី
នាយកដ្ឋានអប់រំ



VICTORIA
State Government
Australia



សាលានេះអបអរសាទរដល់លក្ខណៈពិសេសរបស់បុគ្គលនីមួយៗ តាមរយៈកម្មវិធីសិក្សារបស់ខ្លួន។ ការធ្វើដូច្នេះគឺទទួល ស្គាល់ថា សិស្សម្នាក់ៗត្រូវការឲ្យគេនាំឆ្ពោះទៅមុខចាប់ពីចំណុចផ្តើមរបស់សិស្សនោះ។

សារពីនាយកសាលា

វិទ្យាល័យ Camberwell បានរីកដុះដាលតាំងពីមានសិស្សចំនួន ៣៥០ នាក់នាឆ្នាំ ១៩៤១ រហូតដល់ថ្ងៃនេះដែលមាន ចំនួន ១០០០ នាក់ ប្រុសស្រីវ័យក្មេងដែលបន្តលូតលាស់យ៉ាងខ្លាំង។ សហគមន៍នៃសាលារៀនរបស់យើងលើកស្ទួយការ សិក្សានាសតវត្សទី ២១ ហើយមានមោទនភាពចំពោះប្រវត្តិជាយូរលង់ និងប្រពៃណីដ៏សម្បូរបែបរបស់ខ្លួន។

សាលានេះមានអ្នកសិក្សាសម័យថ្មីដែលធ្វើកិច្ចការនៅទីកន្លែងនិងបរិដ្ឋានឯកទេសខុសៗគ្នាជាច្រើន។

យើងព្យាយាមធ្វើឲ្យគ្រប់គ្នាប្រឹង លូតឡើងនិងកាន់តែចេះតាមរយៈកម្មវិធីនានាដូចជាកម្មវិធី LEEP (Launch and Learning, Enrichment and Extension Program) របស់យើង។ ក៏ដូចជាតាមរយៈជម្រើសកម្មវិធីសិក្សាសម្បូរ បែបក្នុងនិងកម្មវិធីសិក្សាបន្ថែម ដែលធ្វើឲ្យសិស្សស្វាគ៌ាល្បួងអ្វីថ្មីៗ ហើយនិងបង្កើនភាពខ្លាំងពូកែក្នុងផ្នែកដែលពួក គេមានចំណង់ចំណូលចិត្ត។

បាវចនារបស់សាលានេះគឺ □Disco Consulere Aliis□ (រៀនយោគយល់ដល់អ្នកដទៃ)។ បាវចនានេះជាគ្រឹះនៃអ្វីៗ ទាំងអស់ដែលយើងធ្វើ និងមានភស្តុតាងនៅក្នុងការផ្តោតការយកចិត្តទុកដាក់របស់សាលាលើទំនាក់ទំនងប្រកប ដោយសេចក្តីគោរព ព្រមទាំងតាមរយៈការប្រាស្រ័យទាក់ទងដែលគេអាចមើលឃើញរវាងមនុស្សគ្រប់រូប តាមរយៈ លក្ខណៈនៃចិត្តរៀនសូត្ររបស់ពួកគេ។

ដោយសាលាយើងផ្តល់គុណតម្លៃលើសមិទ្ធផលដែលទទួលបាន ភាពច្នៃប្រឌិត ការគោរព និងការទទួលខុសត្រូវ យើងផ្តោតការយកចិត្តទុកដាក់ល្បែងការបណ្តុះបណ្តាលអ្នកសិក្សាដែលធ្វើបានល្អ មានការរំពឹងទុកខ្ពស់អំពីខ្លួនឯង ហើយត្រៀមខ្លួនរួចរាល់ក្នុងការចូលរួមធ្វើជាប្រជាពលរដ្ឋដែលសកម្មនិងមានការចូលរួមប្រឡូក។

ជិល ឡូកលិន (Jill Laughlin)
នាយកសាលា



ហេតុអ្វីបានជាជ្រើសយកវិទ្យាល័យ CAMBERWELL?

កម្មវិធីសម្រាប់សិស្សអន្តរជាតិរបស់វិទ្យាល័យ Camberwell ដែលបង្កើតឡើងនៅឆ្នាំ ១៩៥៦ បានជួយឲ្យសិស្សអន្តរជាតិរាប់៣នាក់សម្រេចបានដល់គោលដៅរបស់ពួកគេតាមរយៈការផ្តល់ជម្រើសផ្លូវនានាចូលទៅសាកលវិទ្យាល័យអន្តរជាតិទាំងពួង។

សិស្សអន្តរជាតិរបស់យើងជាច្រើននាក់បានទទួលបានសមិទ្ធិផលខ្ពស់បំផុត បានទទួលយកអាហារូបករណ៍នៅសាកល វិទ្យាល័យម៉ិលប៊ើន និងម៉ូណាស (Melbourne and Monash Universities)។

យើងមានផ្តល់ការគាំទ្រជាច្រើនក្នុងវិស័យអប់រំ និងបុគ្គល ដែលធ្វើឲ្យត្រូវសម្រាប់សិស្សអន្តរជាតិ រួមមាន ៖

- សាលាបង្រៀនភាសានៅនឹងកន្លែងសម្រាប់សិស្សវ័យលើសពី ១៥ ឆ្នាំទៅ។ សាលាបង្រៀនភាសានៅនឹងកន្លែង នេះផ្តល់ការត្រៀមខ្លួនរៀបចំភាសាអង់គ្លេស សម្រាប់ពន្លឿនឲ្យឆាប់ចេះ សម្រាប់ការចូលរៀនថ្នាក់ឆ្នាំទី១០ ហើយនិងការសិក្សាយកវិញ្ញាបនប័ត្រសិក្សាប្រចាំរដ្ឋវិចតូរៀ (Victoria Certificate of Education (VCE))
- អ្នកសម្របសម្រួលសិស្សអន្តរជាតិ និងអ្នកសម្របសម្រួលការស្នាក់នៅតាមផ្ទះគ្រួសារដែលមានការយក ចិត្តទុកដាក់ខ្ពស់។

ស្ថិស្សអន្តរជាតិមានឱកាសចូលរួមក្នុងកម្មវិធីតន្ត្រីដ៏សម្បូរបែបសម្រាប់សិស្សជាង ៣០០ នាក់។

យើងមានផ្តល់កម្មវិធីជាច្រើនស្តីអំពីការរៀនធ្វើជាអ្នកដឹកនាំរបស់សិស្ស។ នេះគ្រួមទាំងការធ្វើឲ្យមែក្រុមសិស្សអន្តរជាតិជា ផ្នែកមួយនៃវេទិកាប្រក្រតីប្រចាំត្រីមាសដែលដឹកនាំដោយសិស្សដែលធ្វើការជាមួយក្រុមការងារនាយកសាលា។

បច្ចុប្បន្ននេះ សិស្សអន្តរជាតិរបស់យើងកំពុងតែមានងារជាជើងឯកក្នុងវិស័យជំរែកតទល់ជាភាសាចិននៅរដ្ឋវិចតូរៀ រួមទាំងអ្នកពូកែជាងគេក្នុងការប្រកួតជំរែកតទល់។

កម្មវិធីសិក្សាដែលលើកទឹកចិត្តឲ្យសិស្សធ្វើបានល្អបំផុត

សាលារបស់យើងផ្តល់ឲ្យសិស្សនូវមូលដ្ឋានគ្រឹះរឹងមាំមួយសម្រាប់ការសិក្សាបន្ថែមទៀតដោយមានជម្រើសមុខវិជ្ជាជា ច្រើន។ មូលដ្ឋានគ្រឹះរឹងមាំអនុញ្ញាតិឲ្យពួកគេជ្រើសយកផ្លូវតាមរយៈសាលាដែលសមស្របបំផុតទៅនឹងចំណង់ចំណូលចិត្ត ជំនាញ សមត្ថភាព និងអាជីពក្នុងពេលអនាគតដែលពួកគេប្រហែលនឹងមាន។

វិទ្យាល័យ Camberwell ប្តេជ្ញាគាំទ្រដល់ការសិក្សារបស់សិស្សគ្រប់រូបតាមរយៈជម្រើសសម្បូរបែបជាច្រើន។ នេះគ្រួមមាន៖

- វិញ្ញាបនប័ត្រសិក្សាប្រចាំរដ្ឋវិចតូរៀ (VCE)
- កម្មវិធីហ្វឹកហ្វាត់ដើម្បីអាចចូលទៅរៀនថ្នាក់ឆ្នាំទី ៨ LEEP និងថ្នាក់ឆ្នាំទី៩ និង ទី ១០។ កម្មវិធីទាំងអស់នេះ មានគោលបំណងដើម្បីបង្កើនសមត្ថភាពសិស្ស និងជួយក្នុងការបង្កើតអនាគតគណិតវិទ្យ និងអ្នកវិទ្យាសាស្ត្រតាម រយៈការធ្វើចំណោទដែលស្មុគស្មាញក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្មនិងគណិតវិទ្យា (Science, Technology, Engineering and Maths (STEM))។
- សិស្សក្នុងកម្មវិធីហ្វឹកហ្វាត់សម្រាប់ចូលរៀនថ្នាក់ឆ្នាំទី ១០ ត្រូវបានគាំទ្រដោយដៃគូក្នុងវិស័យឧស្សាហកម្មនិង ឧត្តមសិក្សា។ នេះរួមមានសាកលវិទ្យាល័យម៉ិលប៊ើន សាកលវិទ្យាល័យច្បេកវិទ្យា Swinburne, Box Hill TAFE ក៏ដូចជាក្រុមហ៊ុនឯកជនដែលមានកិត្តិនាមខ្ពស់។
- ចាប់ពីថ្នាក់ឆ្នាំទី ១០ ឡើងទៅ គ្រប់សិស្សទាំងអស់អាចរៀនបញ្ចើយមុខវិជ្ជា VCE ហើយសិស្សខ្លះត្រូវបានផ្តល់ ឱកាសឲ្យផ្លោះពីថ្នាក់ឆ្នាំទី ១១ ទៅសាកលវិទ្យាល័យផ្ទាល់តែម្តង។





មានជម្រើសដ៏ច្រើនចំពោះសកម្មភាពក្រៅកម្មវិធីសិក្សា

ស៊ិស្សរបស់វិទ្យាល័យ Camberwell អាចរៀនយកចំណេះក្រៅកម្មវិធីសិក្សាតាមចំណង់ចំណូលចិត្តរបស់ខ្លួនក្នុងវិស័យ តន្ត្រី, STEM, ល្ខោន សិល្បៈ និងវិស័យបច្ចេកវិទ្យា។

មានជម្រើសផ្សេងៗសម្រាប់ផ្តល់ជូន។ ឧទាហរណ៍ ការប្តោះដំរំកំសាន្តតាមថ្នាក់នៃឆ្នាំនៅពេលសិស្សនៅថ្នាក់ឆ្នាំទី ៧ ទី ៩ និងទី ១២។ ក៏មានផងដែរការធ្វើដំណើរសិក្សានៅបរទេស ក្នុងក្រុមតន្ត្រី សិល្បៈ ប្រវត្តិសាស្ត្រ និង STEM។

មានឱកាសជាច្រើនផ្តងដៃស្រុមសម្រាប់សិស្សរៀនឲ្យចេះប្រើយ៉ាងតិច ឧបករណ៍ភ្លេង ១ គ្រឿង ហើយចូលក្នុងក្រុមមួយនៃក្រុម ឧបករណ៍ភ្លេងដែលអាចមានចំនួនដល់ ១១ ក្រុម។ សិស្សក៏អាចចូលពាក់ព័ន្ធនិងក្រុមតន្ត្រីនានា ការប្រណាំងប្រជែងនៃ ក្រុមតន្ត្រី និងការប្រគំតន្ត្រីជាច្រើន។

សកម្មភាពដទៃទៀតដែលអាចរកបាន រួមមាន៖

- ក្លឹបនិងកម្មវិធីធ្វើក្រោយពេលចប់ពីសាលា ជាមួយអ្នកអត្តាធិបាយប្រកបដោយវិជ្ជាជីវៈ ដូចជា Lifesaving Victoria (ការសង្គ្រោះជីវិតនៅរដ្ឋវិចតូរៀ)
- ពិធីបុណ្យច្រៀងជាពួករបស់សាលា និងការនិពន្ធតន្ត្រី ២ ដង ក្នុង ១ ឆ្នាំ
- សកម្មភាពកីឡានិងការប្រកួតប្រជែងដ៏សម្បូរបែប
- ពិធីបុណ្យពហុវប្បធម៌ប្រចាំឆ្នាំ ដែលរៀបចំដោយសិស្ស
- ការប្រកួតក្នុងវិស័យជជែកវែកញែកជាភាសាចិនរបស់សាលាទាំងឡាយក្នុងរដ្ឋវិចតូរៀ
- ក្លឹបរាយប៉េងប៉ុងក្រោយពេលចប់ពីសាលានៅថ្ងៃអង្គារ
- ព្រឹត្តិការណ៍សហគមន៍នៅតាមមូលដ្ឋាន។

ការធ្វើឲ្យសុខុមាលភាពនិងការគាំពារជាអាទិភាពមួយ

យើងទំនុកបំរុងសម្រាប់សេចក្តីត្រូវការរបស់សិស្សអន្តរជាតិដោយផ្តល់ការគាំពារក្នុងវិស័យសិក្សា កន្លែងស្នាក់នៅ និងសុខុមាលភាពទូទៅ។

មានសេវាផ្តល់ការគាំពារសុខុមាលភាពសម្រាប់សិស្ស។

ស៊ិស្សអន្តរជាតិម្នាក់ៗមានអ្នកជួយណែនាំម្នាក់ដែលជួបជាមួយសិស្សជារៀងរាល់សប្តាហ៍ដើម្បីណែនាំនិងគាំទ្រដល់ការ សិក្សានិងសុខុមាលភាពរបស់គេ។

ការពិគ្រោះយោបល់អំពីអាជីព ផ្តល់ការនាំផ្លូវនិងការធ្វើតេស្តអំពីអាជីពនៃសិស្សគ្រប់រូប។ មានឱកាសផ្គងដៃក្នុងការទៅ មើលពិព័រណ៍ឧត្តមសិក្សាសម្រាប់អាជីព និងដែលធ្វើប្រចាំឆ្នាំនៅនឹងកន្លែងតែម្តង ដោយមានឱកាសជួបស្ថាប័នផ្តល់ សេវាឧត្តមសិក្សាជាច្រើន។

យើងមានផ្តល់ជូនម្តងក្នុងមួយសប្តាហ៍នូវក្លឹបក្រោយពេលចប់ពីសាលាដែលមានគ្រូឯកទេសជួយបង្ហាត់បង្រៀ។ នេះរួមមានវគ្គនិងជាភ្ញៀវ។ វគ្គនិទាំងនោះនាំមកដល់ថ្នាក់រៀន នូវឱកាសពិសេសគ្មានពីរឲ្យសិស្សរបស់យើងរៀនសូត្រពី អ្នកមានវិជ្ជាជីវៈស្តីអំពីជម្រើសថាត្រូវសិក្សាអ្វីនៅឧត្តមសិក្សា ធនធានសម្រាប់ការរៀនសូត្រ ក៏ដូចជាឱកាសទាក់ទងក្នុង វិស័យកីឡានិងការងារ។

សេវាគាំទ្រផ្សេងទៀតរបស់យើង រួមមាន៖

- អ្នកសម្របសម្រួលសិស្សអន្តរជាតិ ២ នាក់ និងអ្នកសម្របសម្រួលក្នុងវិស័យស្នាក់នៅផ្ទះតាមគ្រួសារម្នាក់
- វគ្គផ្តល់ព័ត៌មានស្តីអំពីសុខុមាលភាព និងការវិវឌ្ឍផ្ទាល់ខ្លួនសម្រាប់សិស្សអន្តរជាតិ
- ការគាំពារសុខុមាលភាព ដែលមានផ្តល់ដោយ៖

    ○ អ្នកពិគ្រោះយោបល់ធ្វើការពេញម៉ោងម្នាក់ក្នុងវិស័យសុខុមាលភាពសិស្ស

    ○ និងអ្នកចិត្តសាស្ត្រម្នាក់ដែលមានទទួលការហ្វឹកហ្វឺនធ្វើជាអ្នកធ្វើការខាងសុខភាពផ្លូវចិត្ត។
- កម្មវិធីមិត្តរួមថ្នាក់ជួយគ្នានិងអ្នកដៃគូ ដើម្បីជួយឲ្យងាយចូលចុះនិងគេក្នុងការរៀនសូត្រក្នុងសាលាទាំងមូល។

ការស្នាក់នៅតាមផ្ទះគ្រួសារ (Homestay) សម្រាប់សិស្សអន្តរជាតិ

សាលានេះមានសំណាងដែលមានគ្រួសារមួយចំនួនធំផ្តល់សេវា Homestay និងដែលមានចិត្តជួយជាប្រចាំ។

គ្រួសារទាំងឡាយរបស់យើងដែលផ្តល់សេវា Homestay ទទួលការទៀជួបជាប្រចាំពីសំណាក់បុគ្គលិកម្នាក់ពីកម្មវិធីសិស្ស អន្តរជាតិនេះ។ យើងក៏ផ្តល់ការណែនាំនិងការរឹតបន្តឹងទុកច្បាស់ៗដល់គ្រួសារទាំងឡាយរបស់យើងដែលផ្តល់សេវា Homestay ដើម្បីគាំទ្រសិស្សដែលជាភ្ញៀវរបស់ពួកគាត់។

គ្រប់គ្រួសារទាំងអស់ដែលផ្តល់សេវា Homestay ដល់សិស្សសាលារដ្ឋនៅរដ្ឋវិចតូរៀ ផ្តល់៖

- កន្លែងរស់នៅដែលមានសុវត្ថិភាព សន្តិសុខ និងដោយរាក់ទាក់
- ផ្ទះដែលស្របតាមស្តង់ដារសុវត្ថិភាពកុមារ (Child Safe Standards)
- បន្ទប់មួយដោយឡែកសម្រាប់ឲ្យសិស្សនោះប្រើផ្ទាល់ខ្លួន
- អាហារបីពេល ក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃ ក្នុងមួយសប្តាហ៍ រួមទាំងអាហារសម្រន់ផង
- សម្ភារៈរួមមានគ្រែ ទូខោអាវ កន្សែងពោះគោ និងកម្រាលពូក
- សម្ភារៈប្រើប្រាស់ក្នុងផ្ទះរួមមានថ្លៃហ្គាស អគ្គិសនី ទឹក ការកំដៅបន្ទប់ និងអ៊ីនធើណិត
- សេវាសម្អាតបន្ទប់សាឡុងដែលប្រើរួម
- ការប្រើបន្ទប់សាឡុងនៅក្នុងលំនៅដ្ឋាន
- សម្ភារៈសម្រួលការសិក្សា ដូចជាតុសរសេរ ភ្លើងបំភ្លឺសម្រាប់រៀននិងទូដាក់សៀវភៅ
- ការចូលរួមក្នុងសម័យជំនួបមាតាបិតា/គ្រូដែលគេធ្វើនៅពេលល្ងាចជួសមុខឲ្យមាតាបិតារបស់សិស្សម្នាក់ៗ។

មាតាម្នាក់នៃអ្នកផ្តល់សេវា Homestay របស់យើង ដែលមានឈ្មោះ Marita Shepherd បាននិយាយដូចខាងក្រោម នេះអំពីកម្មវិធីរបស់យើង៖

"ការផ្តល់ការស្នាក់នៅពិតជាចូលចំណែកដល់វិសាលភាពសហគមន៍ ប៉ុន្តែចំពោះយើង វាជាមោទនភាពដែលមានសិស្សអន្តរជាតិនៅក្នុងផ្ទះដែលគេទាំងអស់គ្នាជាបុគ្គលម្នាក់ៗ ហើយគេសុទ្ធតែល្អអស្ចារ្យទាំងអស់គ្នា"។

ទីតាំងងាយធ្វើដំណើរទៅមក

វិទ្យាល័យ Camberwell មានទីតាំងស្ថិតនៅក្នុងតំបន់ជាយក្រុងមួយឈ្មោះ Canterbury ដែលមានចម្ងាយប្រមាណ ១០ គម ពីមជ្ឈមណ្ឌលទីក្រុងម៉ិលប៊ើន។

លក្ខណៈសម្បត្តិនៃតំបន់មូលដ្ឋាននេះ រួមមាន៖

- ស្រួលទៅជិះរថភ្លើង ទ្រែម (Tram) និងរថយន្តក្រុងសម្រាប់ការធ្វើដំណើរជិត១ទៅកាន់ក្រុងម៉ិលប៊ើន និងមជ្ឈមណ្ឌលនៅតាមតំបន់ដទៃទៀត
- ស្ថិតនៅទីតាំងនៃកន្លែងមានពពណ៌បៃតងដែលគួរឲ្យទាក់ទាញចិត្តនៅក្នុងតំបន់ជាយក្រុងមួយដែលមានសុវត្ថិភាពនិងសន្តិសុខ
- នៅជិតទីធ្លាកីឡា ផ្លូវសម្រាប់ជិះកង់ អាងហែលទឹកនិងសួនកំសាន្ត
- នៅជិតបណ្តុំផ្សារនិងអាជីវកម្ម Camberwell ដោយមានបណ្ណាល័យផងដែរ
- ងាយដើរទៅកន្លែងពេទ្យ និងធនាគារ។



រឿងប្រកបដោយជោគជ័យមួយក្នុងពេលថ្មីៗ

Jiarui (Jerry) Yan ដែលមកពីប្រទេសចិនបានរៀនភាសាអង់គ្លេសបន្ថែម (EAL) រូបវិទ្យា គីមីវិទ្យា គណិតវិទ្យា (Maths Methods) ជីវៈវិទ្យា និងភាសាចិន ហើយទទួលបានពិន្ទុ ATAR 95.5 ដែលខ្ពស់។

Jerry ជាអ្នកទទួលបានរង្វាន់ Resilience and Innovation Award ក្នុង Victorian Global Learning Awards សម្រាប់ឆ្នាំ ២០២១។ Jerry ក៏ជាប្រធានសិស្សអន្តរជាតិនៅវិទ្យាល័យ Camberwell នៅឆ្នាំ ២០១៩ ដល់ ២០២១។

Jerry ចូលរួមយ៉ាងសកម្មក្នុងកីឡាប៉េងប៉ុង ការជិះយន្តហោះ និងអ្វីៗទាំងអស់ដែលជាវិទ្យាសាស្ត្រនិងគីមីវិទ្យា។ សព្វថ្ងៃ Jerry កំពុងរៀននៅសាកលវិទ្យាល័យម៉ិលប៊ើន។

"ខ្ញុំបានរៀននៅវិទ្យាល័យ Camberwell (CHS) ជាសិស្សអន្តរជាតិចាប់ពីថ្នាក់ឆ្នាំទី ៩ ដល់ ទី១២។ ក្នុងអំឡុងពេលនោះ ខ្ញុំបានជួបមនុស្សមួយចំនួនល្អៗណាស់ ដែលស្វាគមន៍ខ្ញុំទៅក្នុងសាលាដោយដៃពីរ ណែនាំខ្ញុំឱ្យឆ្លងកាត់ការលំបាកនានា ហើយជឿជាក់ថាខ្ញុំអាចបានដល់គោលដៅរបស់ខ្ញុំ" Jerry ថ្លែងដូច្នោះ។

"អ្នកទាំងនោះគឺជាសិស្ស គ្រូ និងបុគ្គលិកគាំទ្ររបស់សាលា CHS - ជាសង្គមដ៏គ្រប់គ្នានៅទីនេះ! ជាមួយអ្នកទាំងនោះ ចំពោះដំណើរសិក្សានៅវិទ្យាល័យរបស់ខ្ញុំ គឺខ្ញុំអាចនិយាយបានថាពិតប្រាយៈពេលគួរឲ្យចងចាំបំផុតនៅក្នុងជីវិតរបស់ខ្ញុំ ដែលខ្ញុំបានរីកធំធាត់ចាប់តាំងពីជាសិស្សចប់សាលាបឋមសិក្សា ឈានទៅដឹងរបរទេស លើកទីមួយ រួចទៅជាមនុស្សថ្មី ស្រឡាងនៅសាកលវិទ្យាល័យមួយដែលត្រៀមខ្លួនសម្រាប់អនាគត។ ប្រសិនបើគេអាចបញ្ជូនខ្ញុំឱ្យត្រឡប់ទៅក្រោយ វិញដើម្បីចាប់ផ្តើមសិក្សានៅវិទ្យាល័យឡើងវិញ ខ្ញុំប្រាកដជាមិនទុកចិត្តលើសាលាណាក្រៅពី CHS ឡើយ។"

> ប្រសិនបើគេអាចបញ្ជូនខ្ញុំឱ្យត្រឡប់ទៅក្រោយ វិញដើម្បីចាប់ផ្តើមសិក្សានៅវិទ្យាល័យឡើងវិញ ខ្ញុំប្រាកដជាមិនទុកចិត្តលើសាលាណាក្រៅពី CHS ឡើយ



ការទាក់ទងមកសាលា

Camberwell High School

Prospect Hill Road, Canterbury, Victoria 3126

អ្នកសម្របសម្រួលសិស្សអន្តរជាតិនិងការស្នាក់នៅតាមផ្ទះគ្រួសារ □
Tara Fang, Phoebe Low និង Cathy Addison

នាយករងសាលា □ Maureen Salter

ទូរស័ព្ទលេខ៖ +61 3 9836 0555 Extension 8120
អ៊ីមែល៖ isc@camhigh.vic.edu.au
គេហទំព័រ៖ https://www.camhigh.vic.edu.au

Victorian Government Schools International Student Program

80 Collins Street, Melbourne Victoria 3000, Australia

Tel: +61 3 7022 1000
Email: international@education.vic.gov.au
Web: www.study.vic.gov.au

Published by the International Education Division

Department of Education Melbourne January 2023

© State of Victoria (Department of Education) 2023

CRICOS Provider Name and Code: Department of Education, 00861K